**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

គាំពារសង្គមកម្ពុជា

SOCIAL PROTECTION IN CAMBODIA

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី១៣)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ១៩ ៧០៤នាក់ នៃរោងចក្រ សហគ្រាស ទាំង៦០ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានប្រាក់ឧបត្ថម្ភលើកទី១ស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល ជ្រាបថា ធនាគារឯកទេសវីង នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភលើកទី២ (បើកបញ្ចប់) របស់រាជរដ្ឋាភិបាលទៅលេខទូរស័ព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភលើកទី២ (បើកបញ្ចប់) នេះ នឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួន៖

- ៤០ ៥០០រៀល (១០ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ៨១ ០០០រៀល (២០ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ៣០ថ្ងៃ
- ២០២ ៥០០រៀល (៥០ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ៣១ថ្ងៃ ដល់ ៤៩ថ្ងៃ
- ២៤៣ ០០០រៀល (៦០ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ៥០ថ្ងៃ ដល់ ២ខែ។

ក្រសួងសូមរំឭកថា ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរស័ព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរស័ព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ទាំង៦០ នេះ មិនបានទទួលសារទូរស័ព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរស័ព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ អង្គារ ៩កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ២០២០

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

### ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០

### បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍ ចំនួន ៦០ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល លើកទី២ (បើកបញ្ចប់)

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស ទទួលប្រាក់ឧបត្ថម្ភលើកទី២ (បើកបញ្ចប់) | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 39 |
| 1 | ក្រុមហ៊ុន ហេជ ហ្គា(ខេមបូឌា)ហ្គាម៉ិន ហ្វេកធើរី | ភ្នំពេញ |
| 2 | ក្រុមហ៊ុន ជា វ៉ែយ (ខេមបូឌា) ហ្គាមេន ហ្វេកធើរី | ភ្នំពេញ |
| 3 | ក្រុមហ៊ុន លូសេន ថេកស្តាយ(ខេមបូឌា)ខូ.,អិលធីឌី | ភ្នំពេញ |
| 4 | ក្រុមហ៊ុន ជា ស៊ីណាត ហ្គាមេន ខូ អិលធីឌី | ភ្នំពេញ |
| 5 | ក្រុមហ៊ុន ស្តាយវើតហ្វេសសិន (ខេមបូឌា)ឯ.ក | ភ្នំពេញ |
| 6 | ក្រុមហ៊ុន ឌីអេសអិល2 អេនធើប្រាយ | ភ្នំពេញ |
| 7 | ក្រុមហ៊ុន ប៊ីល អាប់(ខេមបូឌា) មេនូហ្វេកឈ័ររីង លីមីធីត | ភ្នំពេញ |
| 8 | ក្រុមហ៊ុន ស៊ីនចាង ថេក អ៊ីន | ភ្នំពេញ |
| 9 | ក្រុមហ៊ុន អេស ឌីអេវៀហ្វ្គីន អីកែរីស (ខេមបូឌា) | ភ្នំពេញ |
| 10 | ក្រុមហ៊ុន ខូហ៊ីស្គ(ខេមបូឌា)ខូអ៊ិលធីឌី | ភ្នំពេញ |
| 11 | រោងចក្រ អិមធីយេស៍ ហ្គាមេន (ខេមបូឌា)ខូអិលធីឌី | ភ្នំពេញ |
| 12 | ក្រុមហ៊ុន ថបហ្វម (ខេមបូឌា) ខមភេនី លីមីធីត | ភ្នំពេញ |
| 13 | ក្រុមហ៊ុន សេីង យ៉ុង ហ្គាមែនហ្វាក់តូរី ខូអិលធីឌី | ភ្នំពេញ |
| 14 | រោងចក្រ ហ៊ើចាយ.ហ្គាមិនខូអិលធី | ភ្នំពេញ |
| 15 | ក្រុមហ៊ុន ហៀង ម៉ៅ (ខេមបូឌា)ហ្គាម៉ិន | ភ្នំពេញ |
| 16 | ក្រុមហ៊ុន ហ្គូវ៉ (ខេមបូឌា) ខូ អិលធីឌី | ភ្នំពេញ |
| 17 | ក្រុមហ៊ុន អេស.វ៉ាយ អ៊ីមប្រយឌើរី | ភ្នំពេញ |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស ទទួលប្រាក់ឧបត្ថម្ភលើកទី២ (មើកបញ្ចប់) | រាជធានី ខេត្ត |
|---|---|---|
| 18 | ក្រុមហ៊ុន អេ ផ្លាស់ អេ ស៊ី (ខេមបូឌា) ខូអិលធីឌី | ភ្នំពេញ |
| 19 | ក្រុមហ៊ុន វ៉ុលស្ទូ អ៊ីនធើណេសិនណល ខូអិលធីឌី | ភ្នំពេញ |
| 20 | ក្រុមហ៊ុន ម៉ាក ប៉ែក (ខេមបូឌា) ខូអិលធីឌី | ភ្នំពេញ |
| 21 | ក្រុមហ៊ុន អ៊ី.អេច.អិម.អ៊ីហ្សីហូមមេនូហ្វាក់ធីរីង.ឯ.ក | កណ្ដាល |
| 22 | ក្រុមហ៊ុន ដឺ សូល ឃៀ (ខេមបូឌា) ឯ.ក | កណ្ដាល |
| 23 | រោងចក្រ ហ្វ្រេន អូរៀនថល ហ៊្វតវែរអ៊ិនធើណេសិនណល | កណ្ដាល |
| 24 | ក្រុមហ៊ុន ភ៌យ អិម ជី ហ្គាមេន អេកសេស៊ើរី | កណ្ដាល |
| 25 | ក្រុមហ៊ុន ហ៉ង ឌាន មេធៀរៀល ឯ.ក | កណ្ដាល |
| 26 | ក្រុមហ៊ុន ជីនវៃ អ៊ីនដាសស្ទ្រី ខេមបូឌាខូអិលធីឌី | កណ្ដាល |
| 27 | ក្រុមហ៊ុនឃ្វៃ យ៉ាង ខេមបូឌា ខូអិលធីឌី | កណ្ដាល |
| 28 | ក្រុមហ៊ុន ហ៊ុង ស៊ីង ហ្គាម៉ិន (ខេមបូឌា) ឯ,ក_2 | តាកែវ |
| 29 | ក្រុមហ៊ុន ហាជ៌រអ៊ិនធើណេសិនណល(ខេមបូឌា)ឯ.ក | តាកែវ |
| 30 | ក្រុមហ៊ុន ហ្វ្រេសហ្វូល(ខេមបូឌា)ថេកស្ទាយ ខូ.អិលធីឌី | តាកែវ |
| 31 | ក្រុមហ៊ុន សូឡាម៉ុដា (ខេមបូឌា) ហ្គាមេន ខូអិលធីឌី | តាកែវ |
| 32 | ក្រុមហ៊ុន ហ្ស៊ីជាងហូមភ័ញហ្វើនីឈើរ ឯ.ក | ព្រះសីហនុ |
| 33 | ក្រុមហ៊ុន ចេជាងឌារីណូ(ខេមបូឌា)ហ្វើនីឈើរឯក | ព្រះសីហនុ |
| 34 | ក្រុមហ៊ុន ខេមបូឌាន សាន់ភ៌យ ហ្គាមេន ខូអិលធីឌី | ព្រះសីហនុ |
| 35 | ក្រុមហ៊ុន វីននឹងគ្រាហ្វនឡេតជីវែរ(ខេមបូឌា) ខូអិលធីឌី | កំពង់ស្ពឺ |
| 36 | ក្រុមហ៊ុន ជាគធេច(ខេមបូឌា)ឯ.ក | កំពង់ស្ពឺ |
| 37 | ក្រុមហ៊ុន តៃអ៊ីហ្ស៊ី អ៊ិនធីណាស្យិនណលខូ.,អិលធីឌី | ពោធិ៍សាត់ |
| 38 | ក្រុមហ៊ុន អរិន មេនូហ្វេកធីរីង ( ខ្មែរ ) | ព្រៃវែង |
| 39 | ក្រុមហ៊ុន ខេមបូឌានស៊ីកនេតឈើរ ថេកស្ទាយ ឯ ក | ស្វាយរៀង |
| ខ. វិស័យទេសចរណ៍ | | 21 |
| 40 | ក្រុមហ៊ុន ណាយស៍ អ៊ិនធើណេសិនណល ត្រាវែល អេន ធួរ | ភ្នំពេញ |
| 41 | ក្រុមហ៊ុន ៥ អូស៊ិន ខូអិលធីឌី | ភ្នំពេញ |
| 42 | ក្រុមហ៊ុន អ៊ែរ.តេ.អ៊ែរ ទួរស៍ | ភ្នំពេញ |
| 43 | សណ្ឋាគារប៉ាស៊ីហ្វិក | ភ្នំពេញ |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស ទទួលប្រាក់ឧបត្ថម្ភលើកទី២ (លើកបញ្ចប់) | រាជធានី ខេត្ត |
|---|---|---|
| 44 | ភោជនីយដ្ឋាន អាយរ៉ុន ឆេហ្វ អេហ្វ&ប៊ី (ខេមបូឌា)ឯ.ក | ភ្នំពេញ |
| 45 | ក្រុមហ៊ុន ឥណ្ឌូឆាយណា ស៊ើវីសស៍ (ខេមបូឌា) លីមីតធីត | ភ្នំពេញ |
| 46 | សណ្ឋាគារ អេនិក ប៊ូធិក ហូថេល | ភ្នំពេញ |
| 47 | ក្រុមហ៊ុន អេច ឌី រ៉ក កាហ្វេ & សប | សៀមរាប |
| 48 | ខហ្វហ្វី ខនសិប (ខេមបូឌា) លីមីធីត | សៀមរាប |
| 49 | ក្រុមហ៊ុន ម៉ុនស៊ូន អេស៊ាន ប៊ីស្ត្រូ | សៀមរាប |
| 50 | ក្រុមហ៊ុន ជាតិថាតា អង្គរ | សៀមរាប |
| 51 | ក្រុមហ៊ុន អង្គរកែលេសរីហ្សត និងស្ប៉ា | សៀមរាប |
| 52 | សណ្ឋាគារសោមាទេវីអង្គររីសត & ស្ប៉ា | សៀមរាប |
| 53 | ក្រុមហ៊ុន ខ្មែរអង្គរហូថែលគូអិលធីឌី | សៀមរាប |
| 54 | ក្រុមហ៊ុន 2អិល2 ផាតនើរ | សៀមរាប |
| 55 | សណ្ឋាគារ អង្គរ ហូតែល គ្រុប(សណ្ឋាគារ អប្សរា ផាឡេស) | សៀមរាប |
| 56 | សណ្ឋាគារ តារា អង្គរ | សៀមរាប |
| 57 | សណ្ឋាគារ អង្គរប៉ារ៉ាឌី | សៀមរាប |
| 58 | ក្រុមហ៊ុន ថ្ងៃបាំងឆត្រ៍ រីសត | កែប |
| 59 | ក្រុមហ៊ុន ចុងក្រោយនៃពិភពលោក | កែប |
| 60 | សណ្ឋាគារ រ៉ក់រ៉ូយ៉ាល់_9 | កែប |